- ខេត្តកំពត ១០០.០០០.០០០៛០០ ( មួយរយលានរៀលគត់ )
- ខេត្តកំពង់ធំ ១៧៥.០០០.០០០៛០០ ( មួយរយចិតសិបប្រាំលានរៀលគត់ )
- ខេត្តកំពង់ឆ្នាំង ៧៧.០០០.០០០៛០០ ( ចិតសិបប្រាំពីរលានរៀលគត់ )
- ខេត្តតាកែវ ៧០.០០០.០០០៛០០ ( ចិតសិបលានរៀលគត់ )

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តដែលពាក់ពន្ធ័ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយ ព្រះហស្តលេខានិងចុះហត្ថលេខា តទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៤៩ អនក្រ

## ស្តីពីការផ្ទេរឥណទានចំណាយ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីអំពីប្រពន្ធ័ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ ហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា ១ :** អនុញ្ញាតអោយផ្ទេរឥណទាន ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ( ឥណទានសំរាប់សាលាមធ្យមសិក្សាបច្ចេកទេសឧស្សាហកម្ម ) ជូនទៅក្រសួង អប់រំ យុវជន និង កីឡានូវបរិមាណដូចខាងក្រោម :

- ជំពូក ១០ : ២៣.០៤៨.៦៨៣ " បៀវត្ស និង ប្រាក់បំណាច់ "
- ជំពូក ១១ : ២៣.៥៨១.០០០ " ចំណាយដំណើរការរដ្ឋបាលសំភារៈផ្គូសជុលតូច "
- ជំពូក ៣១ : ៣.០៩០.០០០ " អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និងវប្បធម៌ "
- ជំពូក ៥១ : ២.០០០.០០០ " ឥណទានទិញសំភារៈ "

សរុប : ៥១.៧១៩.៦៨៣ ( ហាសិបមួយលានប្រាំពីររយដប់ប្រាំបួនពាន់ប្រាំមួយរយសែសិបបីរៀល )

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា មានភារកិច្ចអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃឡាយ ព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៥០ អនក្រ
## ស្តីពីការលុបចោលលិខិតបទដ្ឋានចំនួនបី ដែលមិនសមស្របរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤